**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ៖ បព ១៣៤/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃការចូលរួមរបស់ ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅក្នុងកិច្ចពិភាក្សាទូទៅនៃមហាសន្និបាត អ.ស.ប. លើកទី៨១ នៅទីក្រុងញូវយ៉ក

តាមការចាត់តាំងរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា ចូលរួមកិច្ចពិភាក្សាទូទៅ នៃមហាសន្និបាតអង្គការសហប្រជាជាតិ លើកទី៨១ (UNGA 81) ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៦ នៅទីស្នាក់ការកណ្តាល អ.ស.ប. នាទីក្រុងញូវយ៉ក ក្រោមមូលបទ «**ស្តារទំនុកចិត្តឡើងវិញ គ្រប់គ្រងបរិវត្តកម្ម៖ អង្គការសហប្រជាជាតិដែលសម្រេចលទ្ធផលសម្រាប់ទាំងអស់គ្នា**»។

កិច្ចពិភាក្សាទូទៅនៃមហាសន្និបាត អ.ស.ប. លើកទី៨១ បានប្រមូលផ្តុំថ្នាក់ដឹកនាំពិភពលោកក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងដោះស្រាយបញ្ហាប្រឈមសកលដែលកំពុងកើនឡើង រួមមាន ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ ការប្រែប្រួលអាកាសធាតុ វិសមភាព និងការផ្លាស់ប្តូរផ្នែកបច្ចេកវិទ្យាយ៉ាងឆាប់រហ័ស។ ក្នុងបរិបទនេះ បណ្តារដ្ឋសមាជិកបានបញ្ជាក់ជាថ្មីពីភាពចាំបាច់ដាច់ខាតនៃការស្តារទំនុកចិត្តលើស្ថាប័នពហុភាគី ការគោរពតាមគោលបំណង និងគោលការណ៍នៃធម្មនុញ្ញ អ.ស.ប. និងការធានាថា អ.ស.ប. នៅតែជាស្ថាប័នដែលប្រកាន់ខ្ជាប់នូវគោលការណ៍ តំណាងឲ្យទាំងអស់គ្នា មានប្រសិទ្ធភាព និងមានសមត្ថភាពក្នុងការផ្តល់ជូននូវសន្តិភាព សន្តិសុខ ការអភិវឌ្ឍប្រកបដោយចីរភាព និងវិបុលភាពរួមសម្រាប់ទាំងអស់គ្នា។

ក្នុងការថ្លែងបទអន្តរាគមន៍ជាតិរបស់កម្ពុជា **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអបអរសាទរចំពោះឯកឧត្តម បណ្ឌិត Khalilur Rahman ក្នុងឱកាសដែលត្រូវបានជ្រើសតាំងជាប្រធានមហាសន្និបាត អ.ស.ប. លើកទី៨១ និងបានសម្តែងការគោរពចំពោះ ឯកឧត្តម António Guterres អគ្គលេខាធិការ អ.ស.ប. ចំពោះការដឹកនាំដ៏ខ្ជាប់ខ្ជួន និងការប្តេជ្ញាចិត្តចំពោះពហុភាគីនិយម។ ដោយផ្អែកលើបទពិសោធន៍របស់កម្ពុជាក្នុងការប្រែក្លាយជម្លោះទៅជាសន្តិភាពយូរអង្វែង តាមរយៈគោលនយោបាយឈ្នះ-ឈ្នះ របស់ **សម្តេចតេជោ ហ៊ុន សែន ឯកឧត្តម**បានសង្កត់ធ្ងន់លើសារៈសំខាន់នៃកិច្ចសន្ទនា ការផ្សះផ្សាជាតិ ការគោរពច្បាប់អន្តរជាតិ និងការដោះស្រាយជម្លោះដោយសន្តិវិធី។

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

ពាក់ព័ន្ធនឹងបញ្ហាព្រំដែនកម្ពុជា-ថៃ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអំពាវនាវឲ្យមានការអនុវត្តឲ្យបានពេញលេញ និងដោយស្មោះត្រង់នូវកិច្ចព្រមព្រៀងទ្វេភាគីដែលមានស្រាប់ រួមមាន សេចក្តីប្រកាសរួមទីក្រុងក្វាឡាឡាំពួរ កិច្ចព្រមព្រៀងកុងសង់ស៊ីសហ្វ៊ុសៀន (Fuxian Consensus) និងសេចក្តីថ្លែងការណ៍រួម ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងការបន្តសកម្មភាពខណ្ឌសីមានិងវាស់វែងព្រំដែននៃគណៈកម្មការព្រំដែនរួម (JBC) ជាប្រញាប់។ **ឯកឧត្តម** ក៏បានគូសបញ្ជាក់ពីការខូចខាតបេតិកភណ្ឌវប្បធម៌ ការបារម្ភចំពោះការគំរាមកំហែងដែលបង្កដោយយុទ្ធភណ្ឌមិនទាន់ផ្ទុះ និងស្ថានភាពមនុស្សធម៌របស់ប្រជាពលរដ្ឋស៊ីវិលកម្ពុជាជាង ២០,០០០ នាក់ ដែលត្រូវបានភៀសសឹក និងមិនទាន់អាចត្រឡប់ទៅផ្ទះសម្បែងវិញបាន។ ចំពោះការទាមទារដែនសមុទ្រ **ឯកឧត្តម**បានបញ្ជាក់ជាថ្មីពីផ្តួចផ្តើមរបស់កម្ពុជាក្នុងដំណើរការនីតិវិធីផ្សះផ្សាដោយបង្ខំក្រោមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ (UNCLOS) បន្ទាប់ពីភាគីថៃបានលុបអនុស្សរណៈនៃការយោគយល់គ្នា ឆ្នាំ២០០១ ដោយឯកតោភាគី ដើម្បីការពារសិទ្ធិដែនសមុទ្រអធិបតេយ្យរបស់កម្ពុជា ស្របតាមច្បាប់អន្តរជាតិ។

លើសពីនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរំលេចពីកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងបទល្មើសឆ្លងដែន រួមទាំងតាមរយៈការធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទអន្តរជាតិស្តីពីការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដោយមានការសហការជាមួយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងបទល្មើស (UNODC) និងអង្គការប៉ូលីសអន្តរជាតិ (INTERPOL) ព្រមទាំងបានប្រកាសពីភាពត្រៀមខ្លួនរបស់កម្ពុជាក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០ ពីថ្ងៃទី១៥-១៦ ខែវិច្ឆិកា ឆ្នាំ២០២៦ នៅរាជធានីភ្នំពេញ។ **ឯកឧត្តម** ក៏បានបញ្ជាក់ជាថ្មីពីការចូលរួមចំណែកយ៉ាងយូរអង្វែងរបស់កម្ពុជាក្នុងបេសកកម្មរក្សាសន្តិភាព អ.ស.ប. ដោយបានបញ្ជូនកងកម្លាំងមួកខៀវកម្ពុជាជាង ១០,០០០ នាក់ ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ។

តាមរយៈការចូលរួមយ៉ាងសកម្ម និងប្រកបដោយស្មារតីស្ថាបនានៅក្នុងមហាសន្និបាត អ.ស.ប. លើកទី៨១ កម្ពុជាបានសង្កត់ធ្ងន់ពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការពង្រឹងពហុភាគីនិយម ការពារធម្មនុញ្ញអង្គការសហប្រជាជាតិនិងច្បាប់អន្តរជាតិ ការពារអធិបតេយ្យនិងបូរណភាពដែនដីរបស់ខ្លួន ព្រមទាំងធ្វើការយ៉ាងស្ថាបនាជាមួយដៃគូអន្តរជាតិ ដើម្បីឈានទៅសម្រេចបាននូវសណ្តាប់ធ្នាប់អន្តរជាតិមួយដែលមានសន្តិភាព បរិយាប័ន្ន ភាពធន់ និងផ្អែកលើវិធានច្បាប់។

នៅក្រៅកិច្ចពិភាក្សាទូទៅ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអញ្ជើញជួបពិភាក្សាការងារទ្វេភាគីជាមួយរដ្ឋមន្ត្រីការបរទេស និងតំណាង នៃប្រទេសអេមីរ៉ាតអារ៉ាប់រួម ហ្វីលីពីន អាស៊ែបៃហ្សង់ វ៉ាន់ដា អ៊ីរ៉ង់ នីហ្សេ និងសហរដ្ឋអាម៉េរិក ក៏ដូចជាជាមួយ ឯកឧត្តម António Guterres និង លោកជំទាវ Louise Mushikiwabo អគ្គលេខាធិការនៃអង្គការអន្តរជាតិផ្លង់កូហ្វូនី (OIF)។ ជំនួបទាំងនេះបានផ្តល់ឱកាសក្នុងការផ្លាស់ប្តូរយោបល់លើទំនាក់ទំនងទ្វេភាគី ការវិវត្តនៃសភាពការណ៍តំបន់ និងអន្តរជាតិ និងវិស័យដែលមានផលប្រយោជន៍ទៅវិញទៅមក។ ឯកឧត្តម ក៏បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចពិគ្រោះយោបល់នយោបាយ រវាងព្រះរាជាណាចក្រកម្ពុជា និងអេមីរ៉ាតអារ៉ាប់រួម និងអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការបង្កើតទំនាក់ទំនងការទូត រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋនីហ្សេ ផងដែរ៕

ថ្ងៃសៅរ៍ ១៥កើត ខែភទ្របទ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៦